ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

----------------

រដ្ឋសភា

# ច្បាប់

## បន្ថែមលើកទី ២

## ទៅលើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

**មាត្រាតែមួយ**

**មាត្រា ១៣៧ ស្ទួន ..**

ដើម្បីការបោះឆ្នោតអាចប្រព្រឹត្តទៅបានសមស្របតាមលក្ខណៈបច្ចេកទេស នៅថ្ងៃអាទិត្យ ទី២៦ ខែកក្កដា ឆ្នាំ១៩៩៨ កាលបរិច្ឆេទ រយៈពេលនិងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៣៧, ៤៨,៥៨,៦១,៦២,៦៣ មាត្រា ១៣៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង មាត្រា ១៣៧ ស្ទួន នៃច្បាប់បន្ថែមលើកទី ១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធ "គ" ដែលមានជូនភ្ជាប់មកជាមួយនេះហើយកាលបរិច្ឆេទរយៈពេល និងលក្ខខណ្ឌដែលមានចែងក្នុងឧបសម្ព័ន្ធ "ក" និង "គ" អាចត្រូវបានកែសម្រួលដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតតាមលទ្ធភាពបច្ចេកទេសជាក់ស្តែង ។

ច្បាប់នេះ ត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័តនៅថ្ងៃទី ៥ ខែឧសភា ឆ្នាំ ១៩៩៨ នាសម័យប្រជុំរដ្ឋសភាលើកទី ៨ នីតិកាលទី ១ ។

ភ្នំពេញ,ថ្ងៃទី ៥ ខែឧសភា ឆ្នាំ១៩៩៨

**ប្រធានរដ្ឋសភា**

ជា ស៊ីម

# ឧបសម្ព័ន្ធ គ
## ដែលជាចំណែកនៃមាត្រា ១៣៧ ស្ទួនពីរ
## នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

**មាត្រា ៣៧ (៥)បន្ថែម ..**

ក្នុងករណីដែលបេក្ខជនឈរឈ្មោះបោះឆ្នោតទទួលមរណភាពឬបាត់បង់សិទ្ធិឈរឈ្មោះបោះឆ្នោតជាបេក្ខជនតំណាងរាស្ត្រដោយប្រការណាមួយ ឈ្មោះបេក្ខជននោះត្រូវជំនួសដោយបេក្ខជនដែលមានឈ្មោះបន្ទាប់នៅក្នុងបញ្ជីបេក្ខជនបំរុង ។

ក្នុងករណីគ្មានបេក្ខជនបំរុងនៅសល់ គណបក្សនយោបាយត្រូវបញ្ជូនឈ្មោះបេក្ខជនថ្មីមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនឱ្យហួសពី ៣ថ្ងៃ ក្រោយពីការបាត់បង់ឬបោះបង់បេក្ខភាពបេក្ខជនរបស់គណបក្ស ។

**មាត្រា ៤៨ (២)បន្ថែម..**

ចំពោះការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រសំរាប់អាណត្តិទី ២ នាថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ១៩៩៨នេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវប្រកាសបិទផ្សាយបញ្ជីបោះឆ្នោតដំបូងយ៉ាងយូរ ៣០ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

ហើយបញ្ជីបោះឆ្នោតផ្លូវការត្រូវបិទផ្សាយឱ្យបានយ៉ាប់រហ័សបំផុតក្រោយពីការប្តឹងតវ៉ាប្តឹងជំទាស់ត្រូវបានបញ្ចប់ជាស្ថាពរ ។

**មាត្រា ៥៨ បន្ថែម..**

ចំពោះការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រសំរាប់អាណត្តិទី ២ នាថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ១៩៩៨នេះ ត្រង់ចំណុចប្រាំពីរ (៧) ថ្ងៃ ដាក់ជំនួសប្រាំ (៥) ថ្ងៃ ។

**មាត្រា ៦១ បន្ថែម..**

ចំពោះការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រសំរាប់អាណត្តិទី ២ នាថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ១៩៩៨នេះ ត្រង់ចំណុចប្រាំពីរ (៧) ថ្ងៃ ដាក់ជំនួសប្រាំ (៥) ថ្ងៃ ។

**មាត្រា ៦២ បន្ថែម.-**

ចំពោះការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រសំរាប់អាណត្តិទី ២ នាថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ១៩៩៨នេះ ត្រង់ចំណុចដប់ (១០) ថ្ងៃ ដាក់ជំនួសប្រាំ (៥) ថ្ងៃ ។

**មាត្រា ៦៣ បន្ថែម.-**

ចំពោះការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រសំរាប់អាណត្តិទី ២ នាថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ១៩៩៨នេះ លុបត្រង់ចំណុចឃ្លា ( បន្ទាប់ពីថ្ងៃបញ្ឈប់ការចុះបញ្ជីបោះឆ្នោតភ្លាម ) ដោយដាក់ជំនួសឃ្លា (យ៉ាងយូរ៣០ថ្ងៃមុនថ្ងៃបោះឆ្នោត ) វិញ ។